អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens



ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ការតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិថ្មីនៅ អ.វ.ត.ក.

បន្ទាប់ពីមានការស្នើតែងតាំងពីឯកឧត្តម António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ទ្រង់បានតែងតាំងលោក Dale LYSAK (ជនជាតិកាណាដា) ជាសហព្រះរាជអាជ្ញាអន្តរជាតិថ្មី។

លោក LYSAK ជំនួសលោកស្រី Brenda J. HOLLIS (ជនជាតិអាមេរិក) ដែលបានលាលែងពីមុខតំណែងក្នុងខែកក្កដា ឆ្នាំ២០២២ និងត្រូវបានជំនួសបណ្តោះអាសន្នដោយសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង លោក Fergal GAYNOR (ជនជាតិ អៀរឡង់) ស្របតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក.។

លោក LYSAK បានបំពេញការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញាពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ ជាជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២។ មុនពេលបំពេញការងារនៅ អ.វ.ត.ក. លោក LYSAK បានបំពេញការងារផ្នែកច្បាប់នៅក្នុងរដ្ឋ California សហរដ្ឋអាមេរិក រយៈពេល ២០ ឆ្នាំ ហើយបច្ចុប្បន្នជាមេធាវីនៅក្នុងក្រុមហ៊ុនច្បាប់មួយនៅទីក្រុង Vancouver ប្រទេសកាណាដា។

លោក LYSAK បានបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រពីសកលវិទ្យាល័យ McGill University និងជាសមាជិកគណៈមេធាវីនៃរដ្ឋ California ព្រមទាំងជាសមាជិកនៃសមាគមច្បាប់នៃរដ្ឋ British Columbia នៃប្រទេសកាណាដា។

###

### កំណត់ចំណាំចំពោះបណ្តាធិការព័ត៌មាន៖

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) គឺជាស្ថាប័នតុលាការក្នុងស្រុកមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ប្រទេសកម្ពុជា។ អ.វ.ត.ក. មានយុត្តាធិការក្នុងការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ នៃក្រមព្រហ្មទណ្ឌកម្ពុជា

ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

បន្ទាប់ពីបញ្ចប់ដំណើរការកាត់ក្ដីរបស់ខ្លួន អ.វ.ត.ក.បានចាប់ផ្ដើមនៅខែមករា ឆ្នាំ២០២៣ ដើម្បីអនុវត្តលើមុខងារដែលនៅសេសសល់សម្រាប់រយៈពេលបីឆ្នាំដំបូង ស្របតាមកិច្ចព្រមព្រៀងបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ នៅក្រោមកិច្ចព្រមព្រៀងបន្ថែមនេះ ចៅក្រមទាំងអស់ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមដើមបណ្ដឹងរដ្ឋប្បវេណី ទាំងជាតិ និងអន្តរជាតិ ត្រូវបំពេញការងារពីចម្ងាយ លើកលែងតែនៅពេលដែលមុខងាររបស់ពួកគេ តម្រូវឱ្យមានវត្តមាននៅអង្គជំនុំជម្រះវិសាមញ្ញ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោក គុណ ចិន្តា
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ
លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧
អ៊ីម៉ែល៖ kun.chenda@eccc.gov.kh
pas@eccc.gov.kh